**សេចក្តីណែនាំ**

**ស្តីពីគោលការណ៍នៃការប្រឡង និងជ្រើសរើស**

**មន្ត្រីរាជការ ~ សិស្ស ~ និស្សិតអាហារូបករណ៍ទៅសិក្សានៅបរទេស សំរាប់ឆ្នាំ២០០៩**

យោង :-ពិធីសាស្ត្រពីកិច្ចការសហប្រត្តិការអប់រំ និងបណ្តុះបណ្តាលសំរាប់ឆ្នាំ ២០០៦-២០១០ រវាងក្រសួងអប់រំ យុវជន និងកីឡា នៃព្រះរាជាណាចក្រកម្ពុជា ជាមួយក្រសួងអប់រំ និង បណ្តុះបណ្តាល នៃ សាធារណរដ្ឋសង្គមនិយម វៀតណាម ចុះថ្ងៃទី ១០ ខែ តុលា ឆ្នាំ ២០០៥

-កិច្ចព្រមព្រៀងស្តីពីសហប្រតិបត្តិការវិស័យអប់រំ រវាងក្រសួងអប់រំ យុវជន និងកីឡា នៃព្រះរាជាណាចក្រកម្ពុជា និងក្រសួងអប់រំ យុវជន និងកីឡា នៃសារធារណៈរដ្ឋប្រជាមានិតចិន សំរាប់រយៈពេល ០៥ឆ្នាំ ចុះថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ២០០៨

-កិច្ចព្រមព្រៀងស្តីពីសហប្រតិបត្តិការវិស័យអប់រំ រវាងក្រសួងអប់រំ យុវជន និងកីឡា នៃព្រះរាជាណាចក្រកម្ពុជា និងសាកលវិទ្យាល័យ DALI នៃសាធារណរដ្ឋប្រជាមានិតចិន សំរាប់ពេល៥ឆ្នាំ ចាប់ពីឆ្នាំ២០០៩ ចុះថ្ងៃទី ១៩ ខែ វិច្ឆកា ឆ្នាំ ២០០៩

-លិខិតជូនដំណឹងពីក្រសួងការបរទេស និងសប្រតិបត្តិការអន្តរជាតិ

-លិខិតជូនដំណឹងពីស្ថានទូតនៃប្រទេសជាមិត្តប្រចាំព្រះរាជាណាចក្រកម្ពុជា

-លិខិតជូនដំណឹងពីស្ថានទូតនៃព្រះរាជាណាចក្រកម្ពុជា ប្រចាំប្រទេសជាមិត្ត

ដើម្បីធានានូវការផ្សព្វផ្សាយអោយបានទូលំទូលាយ និងបកស្រាយអោយបានច្បាស់លាស់ស្តីពីការប្រលង មន្ត្រីរាជការសិស្ស និស្សិតអាហារូបកណ៍ទៅសិក្សានៅបរទេសតាមចំនួនដែលភាគីមិត្តផ្តល់អាហារូបករណ៍ដល់ ព្រះរាជាណាចក្រកម្ពុជាយើង ក្រសួងអប់រំ យុវជន និងកីឡា និងគ្រប់មន្ទីអប់រំ យុវជន និងកីឡា រាជធានី-ខេត្ត នូវគោលការណ៍សំខាន់ៗមួយចំនួនដូចខាងក្រោម :

សិស្ស - និស្សិត និងមន្ត្រីរាជាការដែលមានសញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ ឬសញ្ញាប័ត្រដែលមានតំលៃស្មើ សញ្ញាប័ត្រថ្នាក់ឧត្តមសិក្សា (Bachelor’s Degree) – សញ្ញាប័ត្រម៉ាស្ទ័រ (Master’s Degree) អាចដាក់ពាក្យសុំអារូបករណ៍ដើម្បីចូលរួមប្រលងជ្រើសរើសទៅសិក្សានៅតាមបណ្តាលប្រទេសមួយចំនួនសំរាប់ឆ្នាំ២០០៩ :

## I- ការជ្រើសរើសដោយឆ្លងកាត់ការប្រឡង

### ក- លក្ខខណ្ឌនៃការចុះឈ្មោះជាបេក្ខជន

- **សំរាប់ថ្នាក់ក្រោយឧត្តមសិក្សា (ម៉ាស្ទ័រ)**

១. បេក្ខជនទាំងពីរភេទត្រូវមានសញ្ជាតិខ្មែរ

២. មានអាយុមិនលើសពី : ៣៥ឆ្នាំ (សំរាប់ប្រទេសរុស្ស៊ី ជប៉ុន ចិន)

៤០ឆ្នាំ (សំរាប់ប្រទេសវៀតណាម)

៣. មានសញ្ញាប័ត្រឧត្តមសិក្សា (Bachelor's Degree)

៤. បេក្ខជនត្រូវចេះភាសា :

- អង់គ្លេស (សំរាប់និស្សិតទៅសិក្សានៅប្រទេសចិន ជប៉ុន សឹង្ហបុរី ម៉ាឡេស៊ី ឥណ្ឌូនេស៊ី)
- រុស្ស៊ី (សំរាប់និស្សិតទៅសិក្សានៅសហព័ន្ធរុស្ស៊ី)
- វៀតណាម (សំរាប់និស្សិតទៅសិក្សានៅប្រទេសវៀតណាម)

៥. ត្រូវមានសុខភាពល្អបរិបូរណ៍ទាំងកាយសម្បទា និងសតិបញ្ញា

- **សំរាប់ថ្នាក់ឧត្តមសិក្សា មធ្យមសិក្សាបច្ចេកទេស និងថ្នាក់បណ្តុះបណ្តាលវិជ្ជាជីវៈ**

១. បេក្ខជនទាំងពីរភេទត្រូវមានសញ្ជាតិខ្មែរ

២. មានអាយុមិនលើសពី : ៣៥ឆ្នាំ (សំរាប់ប្រទេសវៀតណាម និងឡាវ)

២៧ឆ្នាំ (សំរាប់ប្រទេសរុស្ស៊ី)

២៥ឆ្នាំ (សំរាប់ប្រទេសចិន)

២១ឆ្នាំ (សំរាប់ប្រទេសជប៉ុន)

៣. មានសញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ ឬសញ្ញាប័ត្រដែលមានតម្លៃស្មើ

៤. បេក្ខជនត្រូវចេះភាសា : អង់គ្លេស (សំរាប់និស្សិតទៅសិក្សានៅប្រទេសចិន ជប៉ុន សឹង្ហបុរី ម៉ាឡេស៊ី)

៥. ត្រូវមានសុខភាពល្អបរិបូរណ៍ទាំងកាយសម្បទា និងសតិបញ្ញា

### ខ- វិញ្ញាសាប្រឡង

- **ថ្នាក់ក្រោយឧត្តមសិក្សា (ម៉ាស្ទ័រ)**

| ល.រ | ប្រទេស | វិញ្ញាសាប្រឡង | |
|---|---|---|---|
| ១ | ចិន | វប្បធម៌ទូទៅ | ភាសាអង់គ្លេស |
| ២ | ជប៉ុន | វប្បធម៌ទូទៅ | ភាសាអង់គ្លេស |
| ៣ | ឥណ្ឌូនេស៊ី | វប្បធម៌ទូទៅ | ភាសាអង់គ្លេស |

- ថ្នាក់ឧត្តមសិក្សា

| ល.រ | ប្រទេស | វិញ្ញាសាប្រឡង | | | |
|---|---|---|---|---|---|
| ១ | ចិន | គណិតវិទ្យា | ភាសាអង់គ្លេស | | |
| ២ | ជប៉ុន | គណិតវិទ្យា | ភាសាអង់គ្លេស | | |
| ៣ | រុស្ស៊ី | គណិតវិទ្យា | វប្បធម៌ទូទៅ | | |
| ៤ | សឹង្ហបុរី | គណិតវិទ្យា | ភាសាអង់គ្លេស | | |
| ៥ | ម៉ាឡេស៊ី (Petronas) | គណិតវិទ្យា | ភាសាអង់គ្លេស | | |
| ៦ | ឡាវ | វប្បធម៌ទូទៅ | អក្សរសាស្ត្រខ្មែរ | ផ្អែកលើកិច្ចព្រមព្រៀង២០០៤-២០០៨ | |
| ៧ | វៀតណាម | វប្បធម៌ទូទៅ | គណិតវិទ្យា | រូបវិទ្យា | គីមីវិទ្យា |

## II- ការជ្រើសរើសដោយឆ្លងកាត់គណៈកម្មការជ្រើសរើសរបស់ក្រសួង

អាហារូបករណ៍មួយចំនួន ក្រសួងឬភាគីមិត្តកំណត់អោយជ្រើសរើសបេក្ខជនបញ្ជូនទៅសិក្សា ដូចនេះ ក្រសួងអប់រំ យុវជន និង កីឡា ត្រូវបញ្ជូនឈ្មោះបេក្ខជនទៅអោយភាគីមិត្ត ក្រោយពីបានឆ្លងកាត់គណៈកម្មការជ្រើសរើសរបស់ ក្រសួងរួចមក។

អាហារូបករណ៍ទាំងនោះមាន ដូចខាងក្រោមៈ

- បេក្ខជនថ្នាក់ក្រោយឧត្តមសិក្សាទៅសិក្សានៅសាធារណៈរដ្ឋសង្គមនិយមវៀតណាម សំណុំលិខិតបេក្ខជន ត្រូវឆ្លងកាត់គណៈកម្មការជ្រើសរើសក្នុងខែឧសភា។
- បេក្ខជនថ្នាក់ក្រោយឧត្តមសិក្សាទៅសិក្សានៅសហពន្ធ័រុស្ស៊ី
- បេក្ខជនទៅសិក្សានៅសាធារណរដ្ឋគូបា (ក្នុងករណីដែលមានបេក្ខជនតិច)

## III- ការជ្រើសរើសដោយភាគីមិត្តផ្ទាល់

ជារៀងរាល់ឆ្នាំមានប្រទេសមួយចំនួន បានផ្តល់អាហារូបករណ៍សំរាប់សិក្សា និស្សិត មន្ត្រីរាជការ អោយទៅបន្តការសិក្សាគ្រប់កំរិតដែលមានថ្នាក់បណ្ឌិត ថ្នាក់ម៉ាស្ទ័រ ថ្នាក់ឧត្តមសិក្សា ថ្នាក់មធ្យមសិក្សាបច្ចេកទេស ថ្នាក់បណ្តុះបណ្តាលវិជ្ជាជីវៈ ថ្នាក់មធ្យមសិក្សាចំណេះទូទៅ (Secondary Three Education) និងកម្មសិក្សារយៈពេលខ្លីនៅបរទេស ដែលជ្រើសរើសដោយភាគីមិត្តផ្ទាល់តាមលក្ខខណ្ឌជាក់ស្តែងរបស់ប្រទេសនីមួយៗ។ ជាទូទៅបេក្ខជនត្រូវចេះភាសាអង់គ្លេស ច្បាស់លាស់ ដូចជាកំរិត TOEL : 500 ពិន្ទុឡើងទៅជាដើម។ ប្រទេសដែលផ្តល់អាហារូបករណ៍មានដូចជា :

១. ប្រទេសជប៉ុន (ASIAN YOUTH FELLOWSHIP) ថ្នាក់ម៉ាស្ទ័រ ឬបណ្ឌិត

២. ប្រទេសបែលហ្ស៊ិក ថ្នាក់ម៉ាស្ទ័រ

៣. សាធារណៈរដ្ឋប្រជាមានិតចិន /UNIESCO (សហការឧបត្ថម្ភថ្នាក់ម៉ាស្ទ័រ)

៤. សាធារណៈរដ្ឋឆែក /UNIESCO (សហការឧបត្ថមថ្នាក់ឧត្តម និងថ្នាក់ម៉ាស្ទ័រ)

៥. ប្រទេសអាល្លឺម៉ង់ ថ្នាក់ម៉ាស្ទ័រ

៦. ប្រទេសអាមេរិក (កម្មវិធីអាហារូបករណ៍ Fulbright) ម៉ាស្ទ័រ

៧. សាធារណៈរដ្ឋឆែក ថ្នាក់ឧត្តម និងថ្នាក់ម៉ាស្ទ័រ

៨. ប្រទេសបាគីស្ថាន ថ្នាក់ឧត្តម

៩. សាធារណរដ្ឋទួរគី ថ្នាក់ឧត្តម

១០. ប្រទេសថៃ ថ្នាក់ឧត្តម និងម៉ាស្ទ័រ

១១. ប្រទេសជប៉ុនក្នុងកម្មវិធី Japanese Development Scholarship (JDS) សំរាប់ថ្នាក់ម៉ាស្ទ័រ

ការផ្សព្វផ្សាយរកបេក្ខជនទៅអង្គភាពនានាអាស្រ័យតាមមុខជំនាញបណ្តុះបណ្តាល និងតាមការកំណត់ពេលវេលាពីភាគីមិត្តផ្តល់អាហារូបករណ៍។

ចំពោះសិស្ស និស្សិត មន្ត្រីរាជការ និងសាធារណជនទាំងអស់ដែលមានបំណង់ចង់បន្តការសិក្សានៅបរទេសត្រូវអនុវត្តតាមការណែនាំខាងលើ។ ចំពោះព័ត៌មានលំអិតជាក់ស្តែងតាមប្រទេសនីមួយៗ ក្រសួងអប់រំ យុវជន និងកីឡា នឹង ធ្វើសេចក្តីជូនដំណឹងទៅគ្រប់ក្រសួង រដ្ឋលេខាធិកាដ្ឋាន គ្រប់មន្ទីរអប់រំ យុវជន និង កីឡា រាជធានី-ខេត្ត គ្រប់សាលា ខេត្ត-រាជធានី ដើម្បីធ្វើការផ្សព្វផ្សាយបន្តអោយបានជ្រួតជ្រាបបន្ថែមទៀត។

បេក្ខជនអាចធ្វើការទាក់ទងផ្ទាល់ជាមួយការិយាល័យអាហារូបករណ៍ និងកម្មសិក្សា នៃនាយកដ្ឋានទំនាក់ទំនងវប្បធម៌ និងអាហារូបករណ៍ដែលមានអាស័យដ្ឋានអាគារលេខ ៨០ មហាវិថីព្រះនរោត្តម (ស្ថិតក្នុងទីស្តីកាក្រសួងអប់រំ យុវជន និងកីឡា)។

ក្រសួងអប់រំ យុវជន និងកីឡា សង្ឃឹមថាឯកឧត្តម អគ្គនាយក លោក លោកស្រីប្រធាននាយកដ្ឋាន លោកនាយក គ្រឹះស្ថានឧត្តមសិក្សា ឯកឧត្តមអភិបាលរាជធានី-ខេត្ត លោក លោកស្រីប្រធានមន្ទីអប់រំ យុវជន និងកីឡាគ្រប់ខេត្ត-រាជធានី លោកនាយក លោកស្រីនាយិកាគ្រប់វិទ្យាល័យទូទាំងរាជធានី-ខេត្ត នឹងជួយផ្សព្វផ្សាយសេចក្តីណែនាំអោយបាន ទូលំទូលាយជាពុំខាន។